ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៤

នៅក្នុងឆមាសទី១នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម លើការដ្ឋានជាច្រើន ដោយផ្សារភ្ជាប់បទដ្ឋានការងាររដ្ឋបាល បច្ចេកទេស នីតិវិធី ហិរញ្ញវត្ថុ និងពាក់ព័ន្ធនឹងការងារមូលដ្ឋានរបស់ថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា ដើម្បីលើកកម្ពស់មុខងារតំណាង មុខងារត្រួតពិនិត្យ និងមុខងារនីតិកម្ម ជាពិសេសការរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំវិសាមញ្ញ ប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៩ ឆ្លងរបាយការណ៍ស្តីពីការអនុវត្តចំណូល-ចំណាយថវិកាជាតិឆ្នាំ២០១៣ និងកំណត់ផែនការអនុវត្តថវិកាជាតិឆ្នាំ២០១៤ របស់ព្រឹទ្ធសភា ការរៀបចំផ្លាស់ប្តូរអគារបំពាក់ និងពង្រីកមធ្យោបាយបន្ថែមក្នុងព្រឹទ្ធសភា ការបណ្តុះបណ្តាលធនធានមនុស្ស ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងសកម្មភាពការងារសង្គម និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើនការសន្សំសំចៃខ្ពស់ បង្កើតសេវាថ្មីៗ កសាងគោលនយោបាយនានា បង្កើនកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ក្នុងរយៈពេលមួយឆមាសនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចាត់ចែងរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន១០លើក ប្រជុំវិសាមញ្ញ ប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០៩លើក ធ្វើបទបង្ហាញ បទឧទ្ទេសនាម សិក្ខាសាលា ពិធីសម្ពោធអគារថ្មី០៣ ខ្នង០៣ជាន់ ជាជំនួយរបស់រដ្ឋាភិបាលចិនជូនដល់ព្រឹទ្ធសភា និងពិធីបំពាក់គ្រឿងឥស្សរិយយស និងមេដាយការងារជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រជុំពិនិត្យ និងឆ្លងឯកសារស្តីពីសេចក្តីកំណត់ និងនីតិវិធីអនុវត្តចំពោះប្រការទាំងឡាយនៃបទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ ប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ប្រជុំពិភាក្សាជាមួយប្រធានគណៈកម្មការនានា និងចូលរួមក្នុងជំនួបសវនាការ ជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ ចូលរួមមហាសន្និបាត លើកទី១៣០

របស់សហភាពអន្តរសភា(IPU) កិច្ចប្រជុំសមាគមអគ្គលេខាធិការសភា(ASGP) នៅប្រទេសស្វីស និងចូលរួមសន្និសីទថ្នាក់ពិភពលោក ស្តីពីសភាអេឡិចត្រូនិច នៅសាធារណរដ្ឋកូរ៉េ និងកិច្ចប្រជុំនៅទីក្រុងOttawa ប្រទេសកាណាដា ចូលរួមប្រជុំពិភាក្សាការងារ និងក្នុងពិធីផ្សេងៗ ព្រមទាំងបានពិនិត្យសម្រេចលើឯកសារផ្សេងៗ ចំនួន៣២១១ច្បាប់ ។

**១.សេវាទ្រទ្រង់មុខងារនីតិកម្ម**

-បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការជំនាញ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ ចំនួន១១ ។

**២.សេវាទ្រទ្រង់មុខងារត្រួតពិនិត្យ៖**

-បានចុះបំពេញការងារអមជាមួយសមាជិក-សមាជិកា គណៈកម្មការនានា របស់ព្រឹទ្ធសភាក្នុងជំនួបសវនាការជាមួយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដើម្បីស្វែងយល់អំពីការអប់រំទាក់ទងនឹងសិទ្ធិមនុស្ស នៅគ្រប់ភូមិសិក្សា ។

**៣.សេវាទ្រទ្រង់មុខងារតំណាង៖**

-បានសហការរៀបចំវេទិកាសាធារណៈចំនួន០៧លើក ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋ នៅខេត្តកណ្តាល ព្រៃវែង កោះកុង ឧត្តរមានជ័យ ស្ទឹងត្រែង និងរាជធានីភ្នំពេញ ស្តីពីការពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការអភិវឌ្ឍមូលដ្ឋាន យេនឌ័រ សេវាសាធារណៈ និងផលប្រយោជន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងស្តីពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងផ្ញើបទឧទ្ទេសនាម ជូននិស្សិតនាយទាហានសកម្មជំនាន់ទី១៦ និងទី១៧ ចំនួន២៤០នាក់ នៅសាលានាយទាហានសកម្មត្បាតពង ។

-ទទួលពាក្យបណ្តឹងចំនួន ១៧ករណី និងបានបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធចំនួន ០៧ករណី ព្រមទាំងបានទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹង របស់ក្រសួងស្ថាប័នពាក់ព័ន្ធបានចំនួន០៩ករណី និងតម្កល់ទុកមិនចាត់ការចំនួន០៧ករណី និងកំពុងពិនិត្យសិក្សាចំនួន០២ករណី ។

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំសមាជិក-សមាជិកាព្រឹទ្ធសភា អញ្ជើញចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេស ចំនួន៣៥៦លើក ដើម្បីសំណេះសំណាល ជួបពិភាក្សា សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ព្យាបាលជំងឺ ចែកប័ណ្ណកម្មសិទ្ធិដីធ្លី ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន ផ្សព្វផ្សាយព័ត៌មាន

និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងកិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗសរុបចំនួន ១៥៦លើក ។

**៤.សេវាទំនាក់ទំនងមុខងារព័ត៌មាន៖**

-រៀបចំបែបបទអមដំណើរគណៈប្រតិភូព្រឹទ្ធសភា ទៅបំពេញបេសកកម្មតាមបណ្ដាខេត្ត-ក្រុងនានា ចំនួន១៦លើក ដើម្បីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋ និងស្រាវជ្រាវព័ត៌មានពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ និងបានចុះបេសកកម្ម ចំនួន២៧លើក ដើម្បីចូលរួមសិក្ខាសាលា ស្រាវជ្រាវប្រមូលព័ត៌មានសម្រាប់ត្រៀមរៀបចំវេទិកា ជូនក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគ ។

**៥.ការងារអន្តរជាតិ៖**

-ទទួលជួបជាមួយសមាជិករដ្ឋសភាជប៉ុន, គណៈប្រតិភូខុទ្ទកាល័យរដ្ឋសភាឡាវ, អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាថៃ, ឯកអគ្គរដ្ឋទូតរុស្ស៊ី និងកាណាដា,ទីប្រឹក្សាស្ថានទូតជប៉ុន, ក្រុមសំណង់ចិន, ក្រុមវិនិយោគិនជប៉ុន និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍វិទ្យាស្ថានសភាកម្ពុជា ។

-វិទ្យាស្ថានសភាកម្ពុជាគាំទ្រលើវគ្គបណ្ដុះបណ្ដាលសម្រាប់ឆ្នាំ២០១៤ ចំនួន០៤វគ្គ ។

-ទទួលដំណើរទស្សនកិច្ចសិក្សារបស់សាស្ត្រាចារ្យ និស្សិត មកពីវិទ្យាស្ថានខេមហ្វឹត ចំនួន៨៧នាក់ និងសាស្ត្រាចារ្យ និស្សិតនៃសាកលវិទ្យាល័យ Aix Marseille ប្រទេសបារាំង ចំនួន១៦នាក់ ។

-បានរៀបចំបែបជូនសមាជិក- សមាជិកា គណៈកម្មការនានា របស់ព្រឹទ្ធសភា បានអញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា ចូលរួមកិច្ចប្រជុំ សន្និបាត សិក្ខាសាលា វេទិកា និងពិធីផ្សេងៗ នៅប្រទេសវៀតណាម ឡាវ ម៉ាឡេស៊ី ប្រ៊ុយណេ ឥណ្ឌូនេស៊ី ថៃ ចិន ជប៉ុន សាធារណរដ្ឋអាស៊ែបៃហ្សង់ សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន សាធារណរដ្ឋបេឡារុស្ស សាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ម៉ិកស៊ិក ស៊ុយអែត និងប្រទេសបារាំង ។

-រៀបចំបែបបទជូនមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅបំពេញទស្សនកិច្ចសិក្សា ចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា វេទិកា កម្មសិក្សា និងវគ្គបណ្ដុះបណ្ដាលនៅប្រទេសវៀតណាម ថៃ ចិន កូរ៉េ សិង្ហបុរី ម៉ាឡេស៊ី ឥណ្ឌា ស្វីស កាណាដា និងអាល្លឺម៉ង់ ។

-មន្ត្រីចំនួន០២រូប បានចូលរួមហ្វឹកហ្វឺនការងារស្រាវជ្រាវរយៈពេល០១ឆ្នាំ នៅវិទ្យាស្ថានសភាកម្ពុជា ។

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា (ឥណ្ឌា ប្រ៊ុយណេ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្ស៊ិក ស្ថានកុងស៊ុលន័រវែស ) ដើម្បីសុំ

អាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៦.ទំនាក់ទំនងសាធារណៈ៖**

-ទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិ ទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NIDA, Hong kong Center សាកលវិទ្យាល័យមេគង្គកម្ពុជា សាកលវិទ្យាល័យន័រតុន និងចំរើនពហុបច្ចេកវិទ្យា ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន២៤១២នាក់ និងសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន១៤២នាក់ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងតំណាងសហគមន៍មកពីខេត្តកំពង់ធំចំនួន៥០នាក់ និងអង្គការអ្នកស្ម័គ្រចិត្តបារាំងចំនួន១៦នាក់ មកទស្សនកិច្ចព្រឹទ្ធសភា ។

-នាំយកសៀវភៅដែលទាក់ទងនឹងកម្រងលិខិតបទដ្ឋានច្បាប់វិមជ្ឈការ វិសហមជ្ឈការរដ្ឋបាលទូទៅ ភាពជាអ្នកដឹកនាំ ទ្រឹស្តីគ្រប់គ្រង និងសៀវភៅផ្សេងៗទៀត ចំនួន២៨៨ក្បាល និងព្រឹត្តបត្រព័ត៌មានព្រឹទ្ធសភា ចំនួន១២០ក្បាល ជូនបណ្ណាល័យសាលាស្រុកខ្សាច់កណ្តាល ។

**៧.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន៣៩វគ្គ (សិក្ខាកាមសរុប ៤៩១នាក់, ប្រុស៣០៧នាក់ ស្រី១៨៤នាក់) ។

-មន្ត្រីចំនួន០៨នាក់ ទទួលអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យចេនឡាកម្ពុជា និងសាកលវិទ្យាល័យអាយ អាយ ស៊ី ។

-វគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន១២វគ្គ (សិក្ខាកាមសរុប ២៧នាក់, ប្រុស១៧នាក់, ស្រី ១០នាក់) ។

-អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន០៧នាក់ នៅប្រទេសអាល្លឺម៉ង់ វៀតណាម និងចិន ។

**៨.ការអភិវឌ្ឍន៍ស្ថាប័ន៖**

-រដ្ឋាភិបាលចិនយល់ព្រមសាងសង់អគារ១ខ្នងជូនព្រឹទ្ធសភា ។

-រដ្ឋសភាវៀតណាម បានបញ្ជូនក្រុមអ្នកឯកទេស០៤នាក់ ចុះមកសិក្សាអំពីការបំពាក់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅក្នុងព្រឹទ្ធសភាកម្ពុជា ។

-រៀបចំពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារ៣ខ្នង ៣ជាន់ ជាជំនួយរបស់រដ្ឋាភិបាលចិន ។

-ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធក្នុងបរិវេណព្រឹទ្ធសភា (ជួសជុលផ្លូវ របង ធ្វើសួនច្បារ តបណ្តាញអគ្គិសនី ទឹក ទូរស័ព្ទ បច្ចេកវិទ្យាព័ត៌មាន) និងកែសម្រួលប្រព័ន្ធទូរទស្សន៍ខ្សែកាបប្រើប្រាស់ផ្ទៃក្នុងព្រឹទ្ធសភា ។

-ការរៀបចំជួសជុលឡើងវិញអតីតអគារសម្ព័ន្ធភាពជាតិឃុំ-សង្កាត់ ធ្វើជាមជ្ឈមណ្ឌលបច្ចេកវិទ្យាព័ត៌មាន និងការបន្តសំអាតម៉ាបនៅអគារចិនថ្មី៣ខ្នង ។

-បញ្ចប់ការផ្ទេរទឹកទន្លេ និងការបំពាក់ធនធានមធ្យោបាយបន្ថែមក្នុងក្របខ័ណ្ឌអគ្គលេខាធិការដ្ឋានទាំងមូល ។

**៩.ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-រៀបចំកសាងគម្រោងថវិកា ឆ្នាំ២០១៥ របស់ព្រឹទ្ធសភា ។

-រៀបចំ និងកែសម្រួលផែនការលទ្ធកម្ម ឆ្នាំ២០១៤ ឆ្លងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-អនុវត្តការងារលទ្ធកម្មសាធារណៈ និងចាត់ចែងបន្តនីតិវិធីលទ្ធកម្មសាធារណៈ ឆ្នាំ២០១៤ ។

-ដោះស្រាយបន្ទុកហិរញ្ញវត្ថុដ៏ធំក្នុងខែមករា និងខែមិថុនា ឆ្នាំ២០១៤ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ (សម្ភាជដាក់ស្លែង ) ។

-ធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូល-ចំណាយថវិកាជាតិ របស់ព្រឹទ្ធសភា ឆ្នាំ២០១៣ និងឆមាសទី១ ឆ្នាំ២០១៤ ។

-បានបញ្ចប់ការងារប្រកាសទ្រព្យសម្បត្តិ ដើមឆ្នាំ២០១៤ (១០៦នាក់) ។

-អនុវត្តការជំរឿនសារពើភ័ណ្ឌឡើងវិញ និងរាយការណ៍ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-បញ្ចប់នីតិវិធីលទ្ធកម្ម (ឯកសណ្ឋាន ប្រេងឥន្ធនៈ សម្ភារការិយាល័យ សម្ភារសំអាតអនាម័យ និងការបោះពុម្ព ) កាត់ឯកសណ្ឋានជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ) ។

-បញ្ចប់ការរៀបចំយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល(២០១៥-២០១៧) និងឯកសារពាក់ព័ន្ធនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

-ធ្វើកាតបើកប្រាក់បៀវត្សATMថ្មី ជូនអតីតសមាជិកព្រឹទ្ធសភា ទីប្រឹក្សា ជំនួយការផ្ទាល់ ជំនួយការអមគណៈកម្មការជំនាញ អ្នកបើកបរ មន្ត្រីក្របខ័ណ្ឌ មន្ត្រីចូលនិវត្តន៍ និងបុគ្គលិកជាប់កិច្ចសន្យាចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅធនាគារACLEDA (ជំនួសANZ) ។

-រៀបចំនីតិវិធីប្រលងផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ និងដំណើរការតាំងស៊ប់ក្នុងមុខតំណាង ។

-មន្ត្រីជាង២០០នាក់ ត្រូវបានវាយតម្លៃ និងតម្លើងកាំប្រាក់ ។

-ការបន្តកិច្ចសន្យាដល់អ្នកជាប់កិច្ចសន្យាតាមអង្គភាពនានា ។

-បញ្ចប់ពង្រាង និងចាប់ផ្តើមធ្វើក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០១៤-២០២៤) និងទស្សនវិស័យនៃដំណើរទៅមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា(២០១៤-២០២៤) ។

-ធ្វើជំរឿន និងរៀបចំតារាងបៀវត្សមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានសម្រាប់ឆ្នាំ២០១៤ ។

-វាយតម្លៃការអនុវត្តផែនការប្រតិបត្តិសម្រាប់ត្រីមាសទី១ និងឆមាសទី១ ឆ្នាំ២០១៤ ។

-ការគិតគូរដល់ដំណើរការ ប្រព័ន្ធការងារ មធ្យោបាយ និងធនធានសម្រាប់គ្រប់អង្គភាព ។

-ចាត់ចែងការផលិត និងផ្សព្វផ្សាយខ្សែវីដេអូខ្លីបអនុស្សាវរីយព្រឹទ្ធសភា នីតិកាលទី៣ ប័ណ្ណជូនពរ និងសារជូនពរក្នុងឱកាសចូលឆ្នាំថ្មី ។

-ការដោះស្រាយសំណូមពរ អនុសាសន៍ និងពាក្យបណ្តឹងទាំងឡាយ ។

-ការរៀបចំរចនាសម្ព័ន្ធការងារ និងការផ្លាស់ប្តូរអាគារធ្វើការក្នុងស្ថានភាពថ្មី និងបន្តកែលម្អសាលប្រជុំ និងការិយាល័យ ។

-ការងារបុគ្គលិកៈ ការចូលនិវត្ត ការសំរួលការកិច្ចក្នុងក្បាលម៉ាស៊ីន ការផ្ទេរក្នុង/ក្រៅស្ថាប័ន ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន៥៧លើក ។

-ថតចម្លងឯកសារ ចំនួន៧៤០សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន១៩៧ក្បាល ដោះស្រាយសំណើថវិកា ចំនួន១៤៥៣សំណើ និងសម្ភារចំនួន៣៨៩សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន ៥៨៤លើក ។

-បានទទួលសម្ភារខូច ម៉ាស៊ីនហ្វូតូកូពី UPS, Keyboard, CPU, Monitor, Printer និងកៅអីវិលតូចធំ ចំនួន៣២គ្រឿង ។ បានប្រគល់ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនហ្វូតូកូពី ម៉ាស៊ីនស្វាយ កុំព្យូទ័រ ព្រីនធ័រ ក្បាលមេគ្រូធុងបាស ទូទឹកកក ទូរស័ព្ទលើតុ តុប្រជុំ តុការិយាល័យ ទូ កៅអី សាឡុង និងទូរទស្សន៍ ចំនួន១៤៥១គ្រឿង និងទឹកថ្នាំម៉ាស៊ីនហ្វូតូកូពី ចំនួន២៥ដប ។ បំពាក់ទូរទស្សន៍ ជើងស្វាយ កង្ហារបឺត ប្តូរទីតាំងទូរទស្សន៍ ចំនួន៦៩គ្រឿង និងបិទលេខកូដ កៅអីវិល តុដែក ទូដាក់ឯកសារ ម៉ាស៊ីនបញ្ចាំងស្វាយ ក្បាលមេគ្រូ និងកាសត្រចៀក ចំនួន២៥៧គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ ទូរស័ព្ទ បន្ទប់ទឹក ប្តូរអំពូល ព្រី កុងតាក់ ឌីសង់ទ័រ ក្រណាត់កៅអី អូតូទ្វារ ដៃទ្វារ សោទ្វារ និងសោតុ ទូ ទុយោអនាម័យ ចំនួន៤៦៣គ្រឿង ។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន៣១៣គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន២៧៧ ប្រធានបទ ។

**II.ទិសដៅការងារឆមាសទី២ ឆ្នាំ២០១៤**

**១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖**

-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា ។

**២.សេវាទ្រទ្រង់មុខងារត្រួតពិនិត្យ/ ព័ត៌មាន៖**

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ។

**៣.សេវាទ្រទ្រង់មុខងារតំណាង៖**

-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

**៤.ការងារអន្តរជាតិ៖**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា ។

-ត្រៀមទទួលគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភាជប៉ុន ។

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស។

-ដំណើររបស់គណៈកម្មការទី៥ទៅចិន ។

-ការអនុវត្តការងារAIPA, IPU,APF,CLV,និងក្រុមមិត្តភាព ។

-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេស សំរាប់ព្រឹទ្ធសភា តាមរយៈសហប្រតិបត្តិការទ្វេភាគី តំបន់ អន្តរជាតិ ឬតាមវិទ្យាស្ថានសភាកម្ពុជា ។

-បន្តសហប្រតិបត្តិការល្អជាមួយទីប្រឹក្សាអាល្លឺម៉ង់ថ្មី និងដៃគូផ្សេងទៀត។

**៥.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-ជំរុញលើកកម្ពស់ចំណេះដឹង ការបើកវគ្គសិក្សាជំនាញ ភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ និងសណ្តាប់ធ្នាប់សាធារណៈ ។

**៦.ការអភិវឌ្ឍន៍ស្ថាប័ន៖**

-បន្តតាមដានគម្រោងសាងសង់អគារថ្មីជាមួយទីប្រឹក្សាពាណិជ្ជកម្មចិន ។

-បន្តអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ឥណ្ឌា និងជប៉ុន ។

-ការរៀបចំបន្តជួសជុលកែលម្អអគារមួយចំនួន និងបរិស្ថានរួមក្នុងស្ថាប័ន ។

**៧.ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-ត្រៀមចូលរួមពិធីដង្ហែព្រះបរមរតនៈកោដ្ឋ(១០,១១,១២កក្កដា) ពិធីបុណ្យភ្ជុំបិណ្ឌ ទិវាប្រារព្ធព្រះរាជពិធីគោរពព្រះវិញ្ញាណក្ខ័ន្ធ ព្រះបរមរតនៈកោដ្ឋ ព្រះរាជពិធីគ្រងព្រះបរមរាជ្យសម្បត្តិរបស់ព្រះមហាក្សត្រ ពិធីបុណ្យឯករាជ្យជាតិ បុណ្យអុំទូក អកអំបុក សំពះព្រះខែ និងទិវាសិទ្ធិមនុស្ស១០ធ្នូ (ការរៀបចំប្រទីប) ។

-ត្រៀមរៀបចំជាបន្តបន្ទាប់ជំនួបរវាងតំណាងគណបក្សប្រជាជនកម្ពុជា និងតំណាងគណបក្សសង្គ្រោះជាតិ ។

-ដាក់ឆ្លងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាឆ្នាំ២០១៥របស់ព្រឹទ្ធសភា ជូនគណៈកម្មការទី២ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិគ្រប់អង្គភាពអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០១៤ ។

-ត្រៀមសំរាប់ឆ្នាំ២០១៥ ការបោះពុម្ពប្រតិទិន ទិនានុលេខន៍ ប័ណ្ណ រថយន្ត ប័ណ្ណជូនពរ ។

-សិក្សាអំពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់៤អង្គភាព ជាជំហានដំបូង ។

-បន្តពង្រឹងដំណើរការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងជំរុញដំណើរការរបស់អង្គភាពសវនកម្មផ្ទៃក្នុង ។

-បន្តអនុវត្តការងារលទ្ធកម្មសម្ភារ សំណង់ សម្រាប់ឆមាសទី២ ។

-បន្តការងារជំរឿនសារពើភ័ណ្ឌជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារបច្ចុប្បន្នភាពរបស់ជាតិ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់ និងជាមូលដ្ឋាន (នាយកដ្ឋានស្រាវជ្រាវទូទៅ នាយកដ្ឋានស្រាវជ្រាវកិច្ចការសភា) ។

-រៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារក្រហម និងអគារផ្សេងៗទៀត ។ ធ្វើបច្ចុប្បន្នភាព និងថែរក្សាឯកសារសហប្រតិបត្តិការជាមួយដៃគូ ។

-តាមដានដំណើរការកសាងអគារជូនកំលាំងនគរបាលឈរជើងនៅព្រំដែនឡាវ-កម្ពុជា (ខេត្តស្ទឹងត្រែង)។

**III.សេចក្តីសន្និដ្ឋាន**

ក្នុងឆមាសទី១នេះ អគ្គលេខាធិកាដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងមមាញឹកក្នុងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំវិសាមញ្ញ និងបន្តសម័យប្រជុំពេញអង្គ លើកទី៥

ដោយបានពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន១១ ឆ្លងរបាយការណ៍ ស្តីពីការអនុវត្តចំណូល-ចំណាយថវិកាជាតិ របស់ព្រឹទ្ធសភា ឆ្នាំ២០១៣ និងកំណត់ផែនការអនុវត្តថវិកាជាតិ ឆ្នាំ២០១៤ របស់ព្រឹទ្ធសភា និងចាប់ផ្តើមឆ្លងយោបល់លើសេចក្តីព្រាងនីតិវិធីអនុវត្តចំពោះប្រការទាំងឡាយនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ ។ ក្នុងកម្មុងនេះ ថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា បានយកចិត្តទុកដាក់ខ្ពស់លើការងារមូលដ្ឋានពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដើម្បីលើកកម្ពស់មុខងារតំណាង មុខងារត្រួតពិនិត្យ និងមុខងារនីតិកម្ម ។ សមាជិក-សមាជិកាព្រឹទ្ធសភា តាមរយៈយន្តការ (គណៈកម្មការ ក្រុមភូមិភាគ ក្រុមសមាជិកា) បានធ្វើចលនាដោយសកម្ម ដើម្បីស្វែងរកព័ត៌មាន អនុវត្តការងារត្រួតពិនិត្យ និងស្វែងយល់អំពីការអនុវត្តច្បាប់នានា ។ ជាពិសេសការរៀបចំវេទិកានៅតាមភូមិភាគ ។ បានបញ្ចប់ការសាងសង់ ព្រមទាំងរៀបចំពិធីសម្ពោធអាគារ០៣ខ្នង ៣ជាន់ និងការផ្លាស់ប្តូរកន្លែងធ្វើការរបស់គណៈកម្មការ និងនាយកដ្ឋាននានា ចំណុះអគ្គនាយកដ្ឋាន ។ ក្រៅពីនេះ បានត្រួតពិនិត្យមើលលើលទ្ធផលនៃការអនុវត្តសកម្មភាពរបស់អគ្គនាយកដ្ឋានទាំងបី និងបានធ្វើការងារអន្តរជាតិប្រកបដោយលទ្ធផល (ជាមួយចិន វៀតណាម កូរ៉េ ស្វីស កាណាដា អាល្លឺម៉ង់ ...) ។

ដំណើរការសុខដុមកម្ម និងប្រក្រតីកម្មការងារ និងការកសាងបរិយាកាសការងារល្អប្រសើរ នៅតែជាអាទិភាពខ្ពស់ ។ ទីកន្លែងធ្វើការ និងមធ្យោបាយការងារត្រូវបានពង្រីក និងបំពាក់បន្ថែមក្នុងបរិមាណ និងគុណភាពមួយថ្មី និងទូលាយជាងមុន ។ ការប្រឈមទាមទារឲ្យបង្ហាញនូវប្រសិទ្ធភាពថ្មី ប្រសិទ្ធផលថ្មី និងគុណភាពថ្មី ក្នុងការងារ ។ ត្រូវចងចាំអំពីការសន្សំសំចៃឲ្យបានខ្ពស់បំផុត ។

ភ្នំពេញ, ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៤

**អគ្គលេខាធិការ**

**អ៊ុំ.សារឹទ្ធ**